**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤៩១១ ព.ណ.គ.ស.........

ថ្ងៃ អង្គារ ២កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលជាប្រធាន ក្រុមហ៊ុន សហគ្រាស អាជីវកម្ម គ្រប់ប្រភេទ និងសាធារណៈ ជនទាំងអស់មេត្តាជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម នឹងចាប់ផ្តើមអនុវត្តប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចាប់ពី***ថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨***តទៅ។ តារាងស្តីពីសេវាសាធារណៈនេះ មានបិទផ្សាយនៅទីស្តីការក្រសួងពាណិជ្ជកម្ម តាមបណ្តានាយកដ្ឋានជំនាញ បញ្ជរបង់ប្រាក់រួមក្រសួងពាណិជ្ជកម្ម និងតាមរយៈគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម www.moc.gov.kh ។

ជាមួយគ្នានេះដែរ ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនបន្ថែមថា៖

១-ក្រសួងពាណិជ្ជកម្ម នឹងបន្តអនុវត្តប្រកាសរួមលេខ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ***រហូតដល់ថ្ងៃអាទិត្យ ១៤កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧*** ។

២-ក្រុមហ៊ុន សហគ្រាស និងអ្នកនាំចេញ ដែលបាននាំចេញទំនិញពីកម្ពុជា ហើយមិនតម្រូវការវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ គឺត្រូវបន្តអនុវត្តខ្លឹមសារប្រកាសរួមលេខ២៣៣ ព.ណ បអព.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទៅក្រៅប្រទេស ដើម្បីក្រសួងពាណិជ្ជកម្មមានមូលដ្ឋានស្រង់ស្ថិតិ និងធ្វើការកាត់សន្និធិវត្ថុធាតុដើមនាំចូលប្រចាំខែរបស់ក្រុមហ៊ុន សហគ្រាស ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលជាប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្ម គ្រប់ប្រភេទ និងសាធារណៈ ជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន ។

សូមអរគុណ!

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible] សហវ.[illegible]

# ប្រកាសរួម

## ស្តីពី

## ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ.ប្រក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៨ស្ទួននៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្ដីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១ .–**

អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្មអនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .–**

សេវាសាធារណៈដែលផ្ដល់ដោយក្រសួងពាណិជ្ជកម្ម ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្ដល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៣ .–**

ក្រសួងពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្ដល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម និងកម្រងសេវាសាធារណៈដែលរួមមានឧបសម្ព័ន្ធនៃប្រកាសរួមនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្ដល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្ដល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្ដឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្ដល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬ អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៤ .-**

ក្រសួងពាណិជ្ជកម្ម ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ ក្រសួងពាណិជ្ជកម្ម ត្រូវពង្រឹង និងពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

ដោយឡែកចំពោះការផ្តល់សេវាសាធារណៈរបស់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវបន្តអនុវត្តតាមយន្តការ និងនីតិវិធីដែលមានស្រាប់រហូតដល់មានការប្រមូលផ្តុំសេវាឱ្យធ្វើឡើងតាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៥ .-**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

រដ្ឋបាលកណ្តាលក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ យោងតាមសមត្ថកិច្ចប្រមូលចំណូលរៀងៗខ្លួន។

នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្តាលក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៧ .-**

ក្រសួងពាណិជ្ជកម្មត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងពាណិជ្ជកម្ម និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៨ .–**

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៩ .–**

ត្រូវបាននិរាករណ៍ប្រកាសរួម ដូចខាងក្រោម ÷

- ប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .–**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ប៉ាន_ស៊ូរស័ក្តិ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

### ភ្ជាប់នឹងប្រកាសរួមលេខ...០៦៣០៧.... សហវ. ប្រក ចុះថ្ងៃទី...២៧... ខែ...វិច្ឆិកា... ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | I. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម | | | |
| | **នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម** | | | |
| | ក. ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | | | |
| ១ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ១ ៦៨០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| ២ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលត្រូវចុះបញ្ជី | ៣០០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| | ខ. ការសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | | | |
| ៣ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ៤៨០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៤ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលបានចុះបញ្ជី | ១៥០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| | គ. ការសុំចុះបញ្ជីកែប្រែ | | | |
| | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | | | |
| ៥ | - ការកែប្រែផ្លាស់ប្តូរភាគហ៊ុន ការបន្ថយដើមទុន ការបង្កើនដើមទុន | ៨០០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៦ | - ការកែប្រែផ្សេងៗ(អភិបាល កម្មវត្ថុអាជីវកម្ម នាមករណ៍ តម្កល់លក្ខន្តិកៈ ទីស្នាក់ការ ។ល។) | ២៤០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៧ | - ពិន័យករណីមិនបានបំពេញបែបបទក្នុងការផ្លាស់ប្តូរ កែប្រែផ្សេងៗ នៅក្រសួងពាណិជ្ជកម្ម | ១ ០០០ ០០០ ៛ | | ១ ដង |
| ៨ | - ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ៤៨០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| ៩ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលបានចុះបញ្ជី | ១០០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |

| លេខរៀង ចំនួន សេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ឃ. ការតម្កល់ប្រតិវេទីប្រចាំឆ្នាំ | | | |
| ១០ | ១ សេវាតម្កល់ប្រតិវេទ័ប្រចាំឆ្នាំ | ៨០ ០០០ ៛ | ១ ថ្ងៃ | ១ ឆ្នាំ |
| ១១ | ២ ការពិន័យចំពោះការមិនតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំ | ២ ០០០ ០០០ ៛ | | |
| ១២ | ង. ការថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម | ៨០ ០០០ ៛ | ៣ ថ្ងៃ | |
| ១៣ | ច. ទទួលពាក្យស្នើសុំអនុវត្តដីការរក្សាការពារ និងទទួលពាក្យសម្របសម្រួលដោះស្រាយវិវាទ | ១ ០០០ ០០០ ៛ | ១ ថ្ងៃ | |
| ១៤ | ឆ. ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស | ៤០ ០០០ ៛ | ១ ថ្ងៃ | ៣ ខែ |
| ១៥ | ជ. លិខិតបញ្ជាក់ផ្សេងៗ ផ្ទេរសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធ (តាមការស្នើសុំ) | ១៦០ ០០០ ៛ | ៣-៥ ថ្ងៃ | ១ ដង |
| ១៦ | ឈ. ការទាញយកវិញ្ញាបនបត្រ ឬ ការទាញយកសម្រង់ព័ត៌មាន ជាថ្មីទៀតពីប្រព័ន្ធស្វ័យប្រវត្តកម្ម | ៨០ ០០០ ៛ | | ១ ដង |
| ១៧ | ញ. ការផាកពិន័យលើការក្លែងបន្លំឯកសារតម្រូវសម្រាប់ការចុះបញ្ជី | ១ ០០០ ០០០ ៛ | | ១ ដង |
| | ដ. ការងារពិគ្រោះយោបល់ផ្នែកច្បាប់ (តាមការស្នើសុំ) | | | |
| ១៨ | ១ សេវាពិគ្រោះយោបល់ចុះបញ្ជីពាណិជ្ជកម្ម ÷ | ៤០០ ០០០ ៛ | ១ ថ្ងៃ | |
| | - ពិនិត្យ និងបញ្ជាក់លើភាពស្របច្បាប់នៃឯកសារតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម | | | |
| | - បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យា ឬ លក្ខន្តិកៈបង្កើតក្រុមហ៊ុន | | | |
| | - ពិនិត្យ និងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន | | | |
| | - ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ការបកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្មនិងឯកសារកែប្រែ លក្ខន្តិកៈ ក្រុមហ៊ុនដែលមានការចាំបាច់ | | | |

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៩ | ២ សេវាពិគ្រោះយោបល់ផ្នែកច្បាប់ទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ÷ | ២០០ ០០០ ៛ | ១ ថ្ងៃ | |
| | - បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យាឬលក្ខន្តិកៈបង្កើតក្រុមហ៊ុន | | | |
| | - ពិនិត្យនិងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន | | | |
| | - ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់បកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្មនិងឯកសារកែប្រែលក្ខន្តិកៈក្រុមហ៊ុនដែលមានការចាំបាច់ | | | |
| ២០ | ៣ សេវារៀបចំលក្ខន្តិកៈក្រុមហ៊ុន(ចុះបញ្ជីពាណិជ្ជកម្មថ្មី និងការកែប្រែលក្ខន្តិកៈ) | ៤០០ ០០០ ៛ | ២ ថ្ងៃ | |